**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៩៤ ប្រក. កសក

# ប្រកាស
## ស្តីពី
## លក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនប្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ១០៩ ប្រក.កសក.ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានឃើញប្រកាសលេខ២២០ ប្រក.កសក.ប ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត
- បានឃើញប្រកាសលេខ០៩០ ប្រក.កសក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ២.-**

ដើម្បីទទួលបាននីត្យានុកូលភាព រាល់សហភាពសហគមន៍កសិកម្ម ត្រូវរៀបចំឱ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនស្របតាមស្ថានភាពជាក់ស្តែងដោយអនុលោមតាមលក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៣.-**

លក្ខន្តិកៈរបស់សហភាពសហគមន៍កសិកម្ម ត្រូវភ្ជាប់ជាចាំបាច់នូវស្លាកសញ្ញាសម្គាល់សហភាពសហគមន៍កសិកម្មដោយអនុលោមតាមគំរូស្លាកសញ្ញាសម្គាល់សហភាពសហគមន៍កសិកម្មកម្ពុជា និងមានឈ្មោះរបស់សហភាពសហគមន៍កសិកម្មសាមី ស្ថិតនៅខាងក្រោមស្លាកសញ្ញាសម្គាល់។

គំរូស្លាកសញ្ញាសម្គាល់សហភាពសហគមន៍កសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ៤.-**

សហភាពសហគមន៍កសិកម្មមានសិទ្ធិបង្កើត និងប្រើប្រាស់ត្រាសម្គាល់របស់សហភាពសហគមន៍កសិកម្មលើឯកសារពាក់ព័ន្ធផ្លូវការរបស់ខ្លួនដោយអនុលោមតាមច្បាប់ស្តីពីសហគមន៍កសិកម្ម។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានកសិឧស្សាហកម្ម ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត និងសហភាពសហគមន៍កសិកម្មត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ..១៨៤.........ប្រក.កសក ចុះថ្ងៃទី១៨.......ខែ.តុលា..ឆ្នាំ២០១៦
ស្តីពីលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម

## គំរូស្លាកសញ្ញាសម្គាល់សម្រាប់សហភាពសហគមន៍កសិកម្ម

**សហភាពសហគមន៍កសិកម្ម**.............................................

**១-ពណ៌ចំនួនប្រាំពីរ** ៖ តំណាងឱ្យគោលការណ៍គ្រឹះទាំងប្រាំពីររបស់សហគមន៍កសិកម្ម

**២-រូបមនុស្សបីនាក់** ៖ តំណាងឱ្យ បុរស នារី និងយុវជន ចាប់ដៃគ្នាសាមគ្គីយ៉ាងជិតស្និទ្ធ ដើម្បីអភិវឌ្ឍសហភាពសហគមន៍កសិកម្មរបស់ខ្លួន

**៣-ពណ៌បៃតង** ៖ តំណាងឱ្យវិស័យកសិកម្ម

**៤-ពណ៌ខៀវ** ៖ តំណាងឱ្យទឹកស្រោចស្រព

**៥-ស.ស.ក** ៖ អក្សរកាត់ជាភាសាខ្មែរ "សហភាពសហគមន៍កសិកម្មកម្ពុជា"

**៦**. CACU ៖ CAMBODIA AGRICULTURAL COOPERATIVE UNIONS

**៧.សហភាពសហគមន៍កសិកម្ម**.....................៖ឈ្មោះរបស់សហភាពសហគមន៍កសិកម្ម សាមីដែលត្រូវបំពេញ។